# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៥៤

អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្តើមសវនាការសាជាថ្មីយ៉ាងខ្លីមួយនៅថ្ងៃចន្ទនាសប្តាហ៍នេះ បន្ទាប់ពីបានឈប់សម្រាកអស់រយៈពេលពីរសប្តាហ៍កន្លងមក ដោយសារតែពិធីបុណ្យជម្រើនព្រះជន្មព្រះមហាក្សត្រ និងការផ្អាកសវនាការពេញមួយសប្តាហ៍ ដើម្បីអនុញ្ញាតឲ្យភាគីមានពេលវេលាច្រើនក្នុងការត្រៀមរៀបចំសម្រាប់ការស្តាប់សក្ខីកម្មរបស់សាក្សីថ្មីៗបន្ទាប់។ ទោះបីជាសាក្សីដែលមានរហស្សនាម 2-TCW-816 ដែលដំបូងឡើយត្រូវបានរៀបចំកាលវិភាគមកផ្តល់សក្ខីកម្មនៅថ្ងៃចន្ទនេះក៏ដោយ ក៏ក្នុងសប្តាហ៍នេះ ពុំមានសាក្សីណាមួយត្រូវបានស្តាប់សក្ខីកម្មរបស់ពួកគេនោះឡើយ នៅក្រោយពេលដែលមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយបានផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ រហូតដល់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ នាពេលខាងមុខនេះ។ សេចក្តីសម្រេចនេះ ត្រូវបានធ្វើឡើងដោយឆ្លើយតបទៅនឹងសំណើរបស់លោក **នួន ជា** សុំឲ្យមានការពិចារណាឡើងវិញជុំវិញសំណើជាលាយលក្ខណ៍អក្សរ ដែលបានស្នើសុំឲ្យមានការផ្អាកសវនាការរយៈពេលបួនសប្តាហ៍ ដើម្បីផ្តល់ពេលវេលាបន្ថែមឲ្យក្រុមមេធាវីរបស់គាត់ ត្រៀមរៀបចំធ្វើការសួរដេញដោលទៅកាន់សាក្សីអង្គហេតុនៃមន្ទីរសន្តិសុខ ស-២១ ដែលនៅសេសសល់។[1] ក្នុងអំឡុងពេលវគ្គសវនាការពេលព្រឹកនៅថ្ងៃចន្ទ អង្គជំនុំជម្រះ

[1] ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** បានធ្វើសំណើមួយកាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ដើម្បីផ្អាកកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង០០២ វគ្គ២ រយៈពេលចំនួនបួនសប្តាហ៍ ដើម្បីឲ្យពួកគេមានពេលវេលាធ្វើការត្រួតពិនិត្យលើបញ្ជីឈ្មោះថ្មីស្តីពីអ្នកទោសដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ដែលបញ្ជីនេះក្នុងនាពេលថ្មីៗនេះ ត្រូវបានផ្សព្វផ្សាយដោយការិយាល័យសហចៅក្រមស៊ើបសួរ (សូមមើលឯកសារ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** ស្តីពី “សំណើជាបន្ទាន់របស់លោក **នួន ជា** ស្នើសុំ

ក៏បានធ្វើការពិចារណាផងដែរលើសំណើមួយរបស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំឲ្យទទួលយកឯកសារថ្មីមួយចំនួនដាក់បញ្ចូលជាភស្តុតាងក្នុងសំណុំរឿង០០២ វគ្គ២។ នៅពេលដែលសវនាការនឹងចាប់ផ្តើមសាជាថ្មីនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ខាងមុខនេះ អង្គជំនុំជម្រះសាលាដំបូងនឹងស្តាប់សក្ខីកម្មរបស់សាក្សី 2-TCW-816 ក្នុងរយៈពេលចំនួនបីថ្ងៃ ហើយបន្ទាប់មកលោក **អាំង ហ្គេចអ៊ាវ** ហៅ **ឌុច** នឹងផ្តល់សក្ខីកម្មបន្ទាប់ក្នុងរយៈពេលចំនួនប្រាំបួនថ្ងៃផងដែរ។[2]

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ម៉ាលេនី ហៃដ៍ (Melanie Hyde), នីកូឡាស មេយខក (Nicholas Maycock), ខេតលីន កាហ្វព្រៀ (Caitlin McCaffrie), នំ វិសុទ្ធ និង តាយ លីណា ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌលដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

---

ពេលវេលាបន្ថែមដើម្បីត្រៀមរៀបចំសម្រាប់ការសួរដេញដោលសាក្សីអង្គហេតុមន្ទីរសន្តិសុខ ស-២១ ដែលនៅសេសសល់ ដើម្បីធានាពីសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌" (ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦) លេខ E402 ។ ភាគីបានធ្វើការពិភាក្សាដេញដោលគ្នាលើសំណើសុំផ្អាកសវនាការនេះកាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ហើយអង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្អាកសវនាការរយៈពេលមួយសប្តាហ៍។ សម្រាប់សេចក្តីសង្ខេបនៃការពិភាក្សាដែលត្រូវបានធ្វើឡើងនៅពេលនោះ សូមមើលរបាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមក្នុងសំណុំរឿង០០២ វគ្គ២ លេខ៥៣ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៥០ (ចុះថ្ងៃទី២ ដល់ទី៥ ខែឧសភា ឆ្នាំ២០១៦) ទំព័រ ៩។

[2] លោក **អាំង ហ្គេចអ៊ាវ** ហៅ **ឌុច** ត្រូវបានអង្គជំនុំជម្រះសាលាដំបូងរកឃើញពិរុទ្ធភាពរបស់គាត់ ហើយត្រូវបានកាត់ទោសឲ្យជាប់ពន្ធនា-គាររយៈពេលចំនួន៣៥ឆ្នាំ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ (សូមមើល "សាលក្រម" របស់អង្គជំនុំជម្រះសាលាដំបូង (ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) លេខ E188 ។ លោក **អាំង ហ្គេចអ៊ាវ** បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះទៅកាន់អង្គជំនុំជម្រះតុលាការកំពូល តែត្រូវបានច្រានចោល។ រីឯការិយាល័យសហព្រះរាជអាជ្ញា ក៏បានធ្វើការប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះផងដែរ ហើយនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងបានបង្កើនរយៈពេលជាប់ពន្ធនាគាររបស់ជនជាប់ចោទរហូតដល់អស់មួយជីវិត សូមមើល "សាលដីកាលើបណ្តឹងសាទុក្ខ" របស់អង្គជំនុំជម្រះតុលាការកំពូល (ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២) លេខ F28 ។